**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# លទ្ធផលនៃជំនួបសន្ទនាតាមប្រព័ន្ធវីដេអូរវាង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋមីយ៉ាន់ម៉ា នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២

៚✵៛

នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបសន្ទនាតាមប្រព័ន្ធវីដេអូជាមួយឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង ប្រធានក្រុមប្រឹក្សារដ្ឋបាលរដ្ឋនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ដើម្បីផ្លាស់ប្តូរទស្សនៈលើមាគ៌ាឆ្ពោះទៅរកការពន្លឿនការអនុវត្តការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច។

**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានថ្លែងអំណរគុណចំពោះ ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង ចំពោះការសម្របសម្រួលទស្សនកិច្ចលើកទី១របស់ប្រេសិតពិសេសនៃប្រធានអាស៊ាន នៅមីយ៉ាន់ម៉ា កាលថ្ងៃទី២១-២២ ខែមីនា ឆ្នាំ២០២២ និងបានគូសបញ្ជាក់នូវបំណងប្រាថ្នាយ៉ាងមុតមាំពីគ្រប់ភាគី ក្នុងការចង់ឃើញនូវវឌ្ឍនភាពក្នុងពេលឆាប់ៗ ដើម្បីសម្រេចបាននូវអាទិភាពបន្ទាន់ចំនួន០៣ នៃការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច ដែលរួមមាន (១) ការបញ្ឈប់អំពើហិង្សា (២) ការផ្តល់ជំនួយមនុស្សធម៌ទៅដល់គ្រប់ប្រជាជនដែលកំពុងតែត្រូវការបំផុត ដោយគ្មានឧបសគ្គរាំង និង (៣) ការកសាងទំនុកចិត្ត និងភាពជឿជាក់ ដើម្បីជំរុញកិច្ចសន្ទនាប្រកបដោយបរិយាបន្ន។

ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង បានវាយតម្លៃខ្ពស់ចំពោះកិច្ចប្រឹងប្រែងរបស់កម្ពុជា ក្នុងការជួយគាំទ្រមីយ៉ាន់ម៉ារកដំណោះស្រាយតាមសន្តិវិធី ចំពោះវិបត្តិដែលកំពុងមាននាពេលបច្ចុប្បន្ន និងបានជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** អំពីសភាពការណ៍ថ្មីៗនៅមីយ៉ាន់ម៉ាដែលរួមមាន ការឆ្លើយតបនឹងអំពើហិង្សាជាបន្តបន្ទាប់ ការប្រកាសពីឆន្ទៈក្នុងការចរចាកិច្ចព្រមព្រៀងបទឈប់បាញ់ជាមួយក្រុមប្រដាប់អាវុធជនជាតិដើមភាគតិច (EAOs) ទាំងអស់ និងការចែកចាយជំនួយវ៉ាក់សាំងកូវីដ-១៩ ព្រមទាំងសម្ភារៈវេជ្ជសាស្ត្រ ទៅដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាពចំនួន ៥៨កន្លែងនៅមីយ៉ាន់ម៉ា។ ឯកឧត្តមមីង អោង ឡាំង បានសន្យាផ្តល់នូវការសម្របសម្រួលជូនដល់ប្រេសិតពិសេសនៃប្រធានអាស៊ាន ដើម្បីជួបសន្ទនាជាមួយក្រុមប្រដាប់អាវុធជនជាតិភាគតិច ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់អំពើហិង្សា។

ស្របពេលនឹងការស្វាគមន៍ចំពោះសុច្ឆន្ទៈដែលបានបង្ហាញដោយ ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការជៀសឱ្យបាននូវការប្រើកម្លាំងជ្រុលហួសហេតុ នៅក្នុងការថែរក្សាច្បាប់ និងសណ្តាប់ធ្នាប់នៅក្នុងសង្គម។ សម្តេចតេជោក៏បានលើកទឹកចិត្តឱ្យរដ្ឋាភិបាលទីក្រុងណៃពីដោ ធ្វើការសម្របសម្រួលបន្ថែមទៀតដើម្បីឲ្យប្រតិបត្តិការផ្តល់ជំនួយមនុស្សធម៌ដំណើរការប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ជាពិសេសនៅក្នុងតំបន់ជម្លោះ ដែលនេះមិនត្រឹមតែជួយសម្រាលទុក្ខលំបាករបស់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយដល់កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយអំពើហិង្សា និងការកសាងទំនុកចិត្តក្នុងការបង្កើតកិច្ចសន្ទនាសន្តិភាពប្រកបដោយបរិយាបន្នផងដែរ។

ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង បានបញ្ជាក់ពីការត្រៀមខ្លួនជាស្រេចរបស់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ ក្នុងការសម្របសម្រួលការចែកចាយជំនួយមនុស្សធម៌ ដែលអាចអនុវត្តនៅដំណាក់កាលដំបូងក្នុងតំបន់សាកល្បងចំនួនពីរ ក៏ដូចជាតំបន់ និងរដ្ឋចំនួនប្រាំងទៃទៀត ដែលត្រូវបានកំណត់ថាជាតំបន់អាទិភាពសម្រាប់ប្រតិបត្តិការមនុស្សធម៌។ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការរបស់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ សម្រាប់យុទ្ធនាការផ្តល់ជំនួយមនុស្សធម៌ និងការចាក់វ៉ាក់សាំងនៅក្នុងតំបន់សាកល្បង ដែលអាចនឹងពង្រីកជាជំហានៗទៅកាន់តំបន់ផ្សេងៗទៀតនាពេលអនាគត។

ពាក់ព័ន្ធនឹងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីជំនួយមនុស្សធម៌នៅប្រទេសមីយ៉ាន់ម៉ា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង បានបញ្ជាក់ថា ប្រធានក្រុមការងារមីយ៉ាន់ម៉ាសម្រាប់ការសម្របសម្រួលជំនួយមនុស្សធម៌នឹងដឹកនាំគណៈប្រតិភូមកចូលរួមនៅក្នុងកិច្ចប្រជុំនេះ។

នាឱកាសជំនួបនេះដែរ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ក៏បានស្វាគមន៍ចំពោះការដោះលែងអ្នកទោសជាង ១៦០០ នាក់ នៅក្នុងអំឡុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីរបស់មីយ៉ាន់ម៉ា ពីខែមេសា និងបានរំលឹកឡើងវិញពីសំណើរបស់សម្តេចតេជោកន្លងមក ដែលសុំដោះលែងអ្នកទោសនយោបាយទាំងអស់ រួមទាំងសាស្ត្រាចារ្យជនជាតិអូស្ត្រាលី ស៊ន ធើនណែល (Sean Turnell) ផងដែរ។ **សម្តេច**ក៏បានស្នើសុំកិច្ចសហប្រតិបត្តិការបន្ថែមទៀតពីសំណាក់ក្រុមប្រឹក្សារដ្ឋបាលរដ្ឋ ក្នុងការសម្របសម្រួលដំណើរទស្សនកិច្ចលើកទី២ របស់ប្រេសិតពិសេសនៃប្រធានអាស៊ាន នៅមីយ៉ាន់ម៉ា ដែលអាចនឹងធ្វើឡើងនៅចុងខែឧសភានេះ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃការអនុញ្ញាតឱ្យប្រេសិតពិសេសបានចូលជួបជាមួយភាគីពាក់ព័ន្ធទាំងអស់នៅមីយ៉ាន់ម៉ា ដែលក្នុងនោះរួមមានលោកស្រី អោង សានស៊ូជី និងលោកអតីតប្រធានាធិបតី វិន មីុន សំដៅជួយបង្កើតបរិយាកាសអំណោយផលសម្រាប់ការចាប់ផ្តើមកិច្ចសន្ទនានយោបាយប្រកបដោយបរិយាបន្ន។ ជាការឆ្លើយតប ឯកឧត្តមនាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីង អោង ឡាំង បានសន្យាពិនិត្យលទ្ធភាពក្នុងការសម្រួលជំនួបជាមួយភាគីពាក់ព័ន្ធទាំងនោះ។

ជាចុងបញ្ចប់នៃកិច្ចសន្ទនានេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការជួយឱ្យមីយ៉ាន់ម៉ា អាចវិលត្រឡប់មកកាន់លទ្ធិប្រជាធិបតេយ្យវិញ ស្របតាមការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច និងសាមគ្គីភាព និងមជ្ឈភាពនៃអាស៊ាន-១០។

ថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២